ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 08 / 2015
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ១១ ខែ សីហា ឆ្នាំ ២០១៥

## សវនាការលើអង្គហេតុ - ថ្ងៃ ៣០៩

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Robynne CROFT**

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Martin KAROPKIN, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Robynne CROFT |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Travis FARR, លោក Joseph Andrew BOYLE, លោក ស្រ៊ា រតនៈ, កញ្ញា សុង ឆវ័ន្ត , លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លីវ សុវណ្ណា, លោក សុន អរុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក |

| |
|---|
| ជេត វណ្ណលី, លោក ពេជ អង្គ, លោក វ៉ែន ពៅ |
| សាក្សី/ដើមបណ្តឹង៖ កាន ថុល (2-TCW-881), ឡូត ស្លួយ (2-TCW-889) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖កញ្ញា សុក សុភ័គមណីកា, កញ្ញា ស្រី ណាក់, កញ្ញា ណី សុមេត្តា, លោក ឡុង ង៉ែត, លោក កើយ វិញគៀម, លោក Pier Francesco POMPEO |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៨.៥៩ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.២៨ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៨ | បញ្ចប់ម៉ោង៖ ១៣.២៩ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣៨ | បញ្ចប់ម៉ោង៖ ១៤.៥៨ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ម៉ោង ៤ និង ៣៤ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ៨.៥៩ | ០៩.០០ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០១ | ០៩.០៣ |
| ការតាំងសំណួរទៅកាន់សាក្សី កាន ថុល (2-TCW-881) | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៣<br>០៩.៤២<br>១០.៤១ | ០៩.៤១<br>១០.៤១<br>១១.៣៧ |
| ការតាំងសំណួរទៅកាន់សាក្សី ឡូត ស្លួយ (2-TCW-889) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៣.៣១<br>១៣.៣៩ | ១៣.៣៩<br>១៦.០២ |
| ការជំទាស់របស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងសំណួរស្តីពីការសម្លាប់អតីតអ្នករដ្ឋការនៃរបប លន់ នល់ នៅទីតាំងឧក្រិដ្ឋកម្មដែលមិនស្ថិតក្នុងវិសាលភាព | មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ | ១៣.៥៤<br>១៣.៥៦<br>១៣.៥៧<br>១៤.០០ | ១៣.៥៦<br>១៣.៥៧<br>១៣.៥៨<br>១៤.០២ |

| | | | |
|---|---|---|---|
| នៃសំណុំរឿង ០០២/០២ | សហមេធាវីនាំមុខ | ១៤.០២ | ១៤.០៣ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅសាក្សី កាន ថុល (2-TCW-881)**

អង្គជំនុំជម្រះបានតាំងសំណួរ មួយចំនួនទៅសាក្សី (2-TCW-881)។ បន្ទាប់មក មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ធ្វើការតាំងសំណួរទៅជាបន្ត។

**ការតាំងសំណួរទៅសាក្សី ឡុត សួយ (2-TCW-889)**

អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាបានតាំងសំណួរទៅកាន់ ឡុត សួយ (2-TCW-889)។

**ការជំទាស់របស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងសំណួរស្តីពីការសម្លាប់អតីតអ្នករដ្ឋការនៃរបប លន់ នល់ នៅទីតាំងឧក្រិដ្ឋកម្មដែលមិនស្ថិតក្នុងវិសាលភាព នៃសំណុំរឿង ០០២/០២**

ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា បានជំទាស់ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាទៅកាន់សាក្សី (2-TCW-889) ដែលបានសួរពាក់ព័ន្ធនឹងការសម្លាប់អតីតអ្នករដ្ឋការនៃរបប លន់ នល់ នៅទីតាំងឧក្រិដ្ឋកម្មដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង 002/02 ។ អង្គជំនុំជម្រះបដិសេធចោលការជំទាស់នេះ ដោយសារសំណួរនេះគឺពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅដែលបានចោទប្រកាន់ជាគោលនយោបាយទូទៅ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចស៊ើបសួរ**

**Reclassified**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9060 | | 00732996-00733059 00728706-00728752 01123664-01123703 | Statement of LAT Suoy (DC-Cam) | P | 00733024 00733021 00733011 00733030 00733031 00733047 | 00728726 00728724 00728716 00728717 00728730 00728731 00728742 00728743 | 01123681 01123679 01123680 01123673 01123685 01123686 01123695 |
| E3/1181 | D366/7.1.497 | 00214486-00214490 00223175-00223177 00612289-00612292 | Base General View of Sector 5 Northwest Zone | P | 00214487 | 00223175 | 00612290 |
| E3/1900 | | 00193556-00193557 00909168-00909169 | S-21 Execution Log, Uncatalogued execution list of 39 prisoners | P | | 00193556 | 00909168 |
| E3/1783 | D376.3 | 00659257-00659262 00498179-00498181 00606764-00606767 | New China News Agency, Chen Yung-Kuei's Cambodia Visit Reported, 22 December 1977 | P | 00659260 | 00498180 | 00606766 |
| E3/7803 | D166/68 | 00267752-00267757 00277819-00277824 00486081-00486085 | Written Record of Interview of KAN Thorl | P | 00267755 | 00277821 | 00486083 |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319/19.3.20 | D119/144 | 01009200-01009219 01031883-01031905 01109330-01109346 | Written Record of Interview of [REDACTED] | SC | 01009215 | 01031901 | 01109343 |
| E3/342 | D288/6.68.1 | 00329596-00330129 | Revised S-21 Prisoner List | P | | 00329598 | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៣)
- អង្គជំនុំជម្រះបានសម្រេចថា ការសួរដេញដោលសាក្សី (2-TCW-889) ពាក់ព័ន្ធនឹងការសម្លាប់អតីតអ្នករដ្ឋការនៃរបប លន់ នល់ នៅទីតាំងឧក្រិដ្ឋកម្មដែលមិនបានរួមបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ គឺពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅដែលបានចោទប្រកាន់។ (១៤.០២)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥។ (១៦.០២)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥

ក្រឡាបញ្ជី | ក្រឡាបញ្ជី

ជា ស៊ីវហ៊ាង | Robynne CROFT